ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



Work Activities

កសវ

ប្រចាំខែកញ្ញា ឆ្នាំ២០១៦



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| - សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការជំរុញភូមិមួយផលិតផលមួយ២០១៦-២០២៦ | ១-២ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| - សិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការវាយតម្លៃលើផលប៉ះពាល់នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | ៣-៥ |
| III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១៦ | ៦-១៣ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៦ | ១៤-១៥ |

# សេចក្តីព្រាងគោលនយោបាយជាតិស្តីពី
## ការជំរុញភូមិមួយផលិតផលមួយ ២០១៦-២០២៦

កាលពីថ្ងៃទី២៩ ខែមិថុនា និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការជំរុញភូមិមួយផលិតផលមួយ ២០១៦-២០២៦** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។



ចលនាភូមិមួយផលិតផលមួយត្រូវបានចាប់ផ្តើមឡើងនៅខេត្ត Oita នៃប្រទេសជប៉ុន នាឆ្នាំ១៩៧៩ ដោយចលនាបានកកើតឡើងក្នុងបរិបទមួយដែលស្ថានភាពរស់នៅរបស់ប្រជាជនជប៉ុនក្នុងខេត្ត Oita ដែលជាខេត្តស្ថិតនៅតំបន់ជនបទដាច់ស្រយាលមានប្រជាជនរស់នៅក្នុងស្ថានភាពក្រីក្រ និងមានចំណាកស្រុកខ្ពស់ ចេញទៅរកការងារធ្វើនៅទីក្រុង ជាពិសេសក្រុមយុវជនក្មេងៗ។ ចលនានេះមានគោលបំណងអភិវឌ្ឍដ្ឋានតាមរយៈការគាំទ្រដល់ធនធានចំណេះដឹង ថវិកា ព័ត៌មាន មធ្យោបាយ និងទីផ្សារដល់ប្រជាជនក្នុងសហគមន៍ក្នុងការផ្តួចផ្តើមគំនិតផលិតនូវផលិតផលមួយរក្សាបានអត្តសញ្ញាណផ្ទាល់របស់ខ្លួន ជាផលិតផលមានគុណភាព មានការវេចខ្ចប់ល្អ និងមានតម្លៃសមស្របក្នុងការបំពេញសេចក្តីត្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស និងទាក់ទាញភ្ញៀវទេសចរណ៍ ដែលទាំងអស់នេះជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មប្រកបដោយចីរភាព រួមចំណែករំដោះប្រជាជនចេញពីភាពក្រីក្រ និងកាត់បន្ថយចំណាកស្រុកនៃក្រុមយុវជនក្មេងៗ។

នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភាគឺក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកក្របខណ្ឌទស្សនៈ

ភូមិមួយផលិតផលមួយ មកអនុវត្តនៅកម្ពុជា ដោយមានការរៀបចំគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ តាមរយៈព្រះរាជក្រឹត្យនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៦ ក្នុងនោះមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធាន ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន និងឯឧត្តម **សុន គន្ធរ** ជាអគ្គលេខាធិការ។

គោលនយោបាយជាតិស្តីពីការជំរុញភូមិមួយផលិតផលមួយ គឺជាផែនទីចង្អុលផ្លូវរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ដែលត្រូវបានធ្វើសមាហរណកម្មក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្នុងការកំណត់ទិសដៅ និងយុទ្ធសាស្ត្រជួយដល់កសិករ ផលិតករ សិប្បករ និងសេវាករ ជាពិសេសសមាគម ឬសហគមន៍អ្នកផ្តល់សេវា ដែលបានចុះឈ្មោះចូលជាសមាជិកនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ។ គោលនយោបាយនេះ នឹងជួយដល់កិច្ចសហការ និងការសម្របសម្រួលនានា រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធជាមួយនឹងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ដែលមានអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ ជាសេនាធិការក្នុងការប្រតិបត្តិមុខងារប្រចាំថ្ងៃនៅថ្នាក់ជាតិ និងមានលេខាធិការដ្ឋាននៅថ្នាក់ក្រោមជាតិដែលជាសេនាធិការនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ រាជធានី-ខេត្ត[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង នាពេលខាងមុខ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការជំរុញភូមិមួយផលិតផលមួយ ២០១៦-២០២៦។

# សិក្ខាសាលាស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការវាយតម្លៃលើផលប៉ះពាល់នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

### ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ៨៨៣៤ នៅក្រសួងរ៉ែ និងថាមពល
### ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

ក្រសួងរ៉ែ និងថាមពល សហការជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី (ក្រុម RIA) បានរៀបចំសិក្ខាសាលាស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការវាយតម្លៃលើផលប៉ះពាល់នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ក្រោមជំនួយបច្ចេកទេសរបស់ ADB លេខ ៨៨៣៤។ សិក្ខាសាលានេះដឹកនាំដោយសហប្រធានគឺ ឯកឧត្តម **ឌិត ទីណា** រដ្ឋលេខាធិការ តំណាងឯកឧត្តមរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយមានអ្នកចូលរួមប្រមាណ ១៥០នាក់ (ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងរ៉ែនិងថាមពល មន្ត្រីកម្មវិធី RIA មកពី ECOSOCC, MoC, MoE, MoT, MEYS, MLVT, MAFF, MPWT, MOH, MIH, PMTC, MEF, PLMUC និងតំណាងរបស់ ADB)។




វាគ្មិននៅក្នុងព្រឹត្តិការណ៍ថ្ងៃនេះ រួមមានឯកឧត្តម **ឌិត ទីណា** រដ្ឋលេខាធិការ តំណាង ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ឯកឧត្តម **ឃឹម ណុលសន** អនុប្រធាន ECO-SOCC, **Ms. Jacqueline Lam** Trade Specialist, Public Management, Finance&Trade Division, Southeast Asia Department, ADB និងឯកឧត្តម **ម៉េង សក្តិធារ៉ា** រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការ



រៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តដែលផ្ដល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើន ដែលជាសមាជិកនៃ OECD (អង្គការអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ) ទទួលស្គាល់យ៉ាងទូលំទូលាយអស់រយៈជាច្រើនទសវត្សមកហើយ និងម្យ៉ាងទៀត ប្រទេស ASEAN ដូចជា វៀតណាម ឡាវ ថៃ ហ្វីលីពិន និងម៉ាឡេស៊ី ដូចជា:

- លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច;
- អ្នកធ្វើសេចក្ដីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យផ្អែកលើការអនុវត្តជាក់ស្ដែង;
- បង្កើនតម្លាភាព និង កសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ;
- ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច

អភិបាលកិច្ចល្អ គឺជាចំណុចកណ្ដាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការ RIA នឹងកាត់បន្ថយការិយាធិបតេយ្យ និងភាពច្រើនហួស/ភាពជាន់គ្នា នៃលិខិតបទដ្ឋានគតិយុត្ត។

កម្ពុជាមិនមានការកំណត់ថេរវេលានៃការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តទេ ដូច្នេះ ទម្លាប់អនុវត្តល្អសម្រាប់ការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនឹងផលិតលិខិតបទដ្ឋានគតិយុត្តកាន់តែល្អ។

ECOSOCC ជាអង្គភាពប្រតិបត្តិRIA មានតួនាទី៖

- ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល ដល់អ្នកអនុវត្ត RIA នៅតាមក្រសួងពាក់ព័ន្ធ



ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- ជួយផ្នែក RIA នៅតាមក្រសួងពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍វាយតម្លៃ RIA លើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត
- បច្ចុប្បន្នកម្ម គោលការណ៍ណែនាំ/កូនសៀវភៅ/សៀវភៅ/គំរូ RIA
- រៀបចំការផ្សព្វផ្សាយបញ្ច្រាបការយល់ដឹងជាសាធារណៈ

- ត្រួតពិនិត្យការអនុវត្ត RIA ថ្នាក់ជាតិ

បច្ចុប្បន្នមានក្រសួងចំនួន១៣( MME, MoC, MoE, MoT, MEYS, MLVT, MAFF, MPWT, MOH, MIH, PMTC, MEF, PLMUC ) ដែលចូលរួមអនុវត្ត កម្មវិធីRIA មានតួនាទី៖

- ចូលរួមវគ្គបណ្ដុះបណ្ដាល RIA ( ក្នុងស្រុក និង ទស្សនៈកិច្ចសិក្សា )
- អនុវត្ត RIA លើសំណើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត (របាយការណ៍វាយតម្លៃបឋម RIA/ របាយការវាយតម្លៃពេញលេញRIA )
- ដាក់របាយការណ៍RIA ជាមួយនឹងសំណើបញ្ញត្តិកម្ម ជូនអ្នកធ្វើសេចក្ដីសម្រេច
- ផ្ដល់ការបណ្ដុះបណ្ដាល /ផ្សព្វផ្សាយ RIA ដល់នាយកដ្ឋាននានានៅក្នុងក្រសួងផ្ទាល់រៀងៗខ្លួន។

ECOSOCC បានរៀបចំសេចក្ដីព្រាងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតក្រុម RIA នៅតាមក្រសួងនានារួចរាល់ហើយ នឹងដាក់ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យសម្រេច៕

## III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១៦ *



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ **ប្រចាំឆមាសទី១ ឆ្នាំ២០១៦**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈុនលី** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នា ឆ្នាំ២០១៦និងឆ្នាំ២០១៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ២,៨% ដែលអាចចាត់ទុកថា ជាកម្រិតទាបបើធៀបនឹងការចែងក្នុងគោលនយោបាយ (៣% - ៥%)។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៦

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា P | សីហា P | កញ្ញា P | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៦ | ខែដូចគ្នាឆ្នាំ | ៣,០% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ២,៨% | ៣,១% | ២,៣% | | | | |
| ២០១៥ | ខែដូចគ្នាឆ្នាំ | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| ២០១៤ | ខែដូចគ្នាឆ្នាំ | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ១,១% | ៣,៩% |

P:តួលេខខែ កក្កដា សីហា កញ្ញា និងប្រចាំឆ្នាំ២០១៦ ជាតួលេខព្យាករណ៍(តាមវិធីសាស្ត្រ **Decomposition**)

តារាង១.២. សន្ទស្សន៍ថ្លៃអតិផរណា និងអត្រារួមចំណែកក្នុងអតិផរណា (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យមឆមាសទី១ ឆ្នាំ២០១៦ | អតិផរណា ឆមាសទី១ ឆ្នាំ២០១៥ |
|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៦៣,៣% | ១៥៨,៩% |
| ម្ហូបអាហារ | ១៩៩,០% | ១៨៨,៥% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៥៥,៤% | ១៤០,៥% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៣៩,៦% | ១៣៣% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ទនៈផ្សេងទៀត | ១២៤,០% | ១២៧,៣% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៤៧,១% | ១៤៣% |
| សុខាភិបាល | ១៣០,៦% | ១២៧,៥% |
| ការដឹកជញ្ជូន | ១០៨,០% | ១១៧,៧% |
| ក្នុងនោះ ប្រេងសាំង | ៨២,០% | ១០១% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | |
|---|---|---|
| ទូរគមនាគមន៍ | ៦៨,៦% | ៦៧,៧% |
| ការកម្សាន្ត និងវប្បធម៌ | ១១៦,៨% | ១១៣% |
| ការសិក្សា | ១៦០,១% | ១៥៩,១% |
| ភោជនីយដ្ឋាន | ២៣៨,៧% | ២២៦% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៣៨,១% | ១៣៨,៨% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

- មុខទំនិញដែលឡើងថ្លៃខ្ពស់មានសាច់គោ ១០,៥% ត្រីស្រស់ ១០,៣% បន្លែ ៥,៩% និងផ្លែឈើ ៥,៧% ។

➡ **អត្រាប្តូរប្រាក់៖**ជារួមអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយវត្ថុបរទេសមានស្ថេរភាព។ ប្រាក់រៀលមានការឡើងថ្លៃធៀបនឹងដុល្លារ បាត និងដុង។

| ប្រភេទ | ចុងឆមាសទី១/២០១៦ | ចុងឆមាសទី១/២០១៥ | បម្រែបម្រួល |
|---|---|---|---|
| **រ/១ដុល្លារ** | ៤០៨៤រ | ៤០៩៨រ | -០,៣% |
| **រ/១បាត** | ១១៦រ | ១២១រ | -៤,១% |
| **រ/១ដុង** | ០,១៨៣រ | ០,១៨៨រ | -២,៧% |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៦ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ៧៣៦៩ប៊ីលានរៀលស្មើនឹង ៥៤% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងនោះ ចំណូលចរន្តមានចំនួន ៧៣៣៣ ប៊ីលានរៀលស្មើនឹង ៦៦% នៃផែនការ និងចំណូលមូលធនចំនួន ៣២ ប៊ីលានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នាចំណូលថវិកាជាតិ កើនឡើង ២៤% ដែលក្នុងនោះ ចំណូលចរន្ត កើនឡើង២៤% ។

➢ ក្នុងចំណូលចរន្ត៖ ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ៦៦១០ប៊ីលានរៀលស្មើនឹង ៥៧% នៃផែនការប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៥ ចំណូលសារពើពន្ធ កើនឡើង ២២% ដែលក្នុងនោះ ពន្ធ និងអាករគយ កើនឡើង ២៧% (តាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កើនឡើង២០%) និងចំណូលពន្ធដារ កើនឡើង ២២% (តាមអគ្គនាយកដ្ឋានពន្ធដារ កើនឡើង១៨%) ។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធតាមឆមាស (២០១៤-២០១៦)

យោងតាមក្រាហ្វចំណូលពន្ធដារមាននិន្នាការថយចុះក្នុងឆមាសទី២។ ក្នុងឆមាសទី១ពន្ធ និងអាករគយ និងពន្ធដារមានកម្រិតប្រហាក់ប្រហែលគ្នា។ ជារួមពន្ធនិងអាករគយ នៅតែមានកម្រិតខ្ពស់ជាងពន្ធដារ ។



តារាង២.១. សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្ត ផែនការ | %Δធៀបនឹងឆ .១ឆ្នាំ២០១៥ | **មុខចំណូល** | អនុវត្ត ផែនការ | %Δធៀបនឹង ឆ.១ ឆ្នាំ២០១៥ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ(រតនាគា)** | ៥៧% | +២២% | **ចំណូលមិនមែនសារពើពន្ធ** | ៣៩% | +៥៣% |
| ✓ពន្ធនិងអាករគយ(**អ.នាគយនិងរដ្ឋាករ**) | ៥៥% | +២០% | ✓កាស៊ីណូ | ៤២% | –៣៤% |
| -ពន្ធគយ (របបនាំចូល) | ៥៣% | +១៤% | ✓អាជ្ញាបណ្ណក្នុងស្រុក | ៣១% | +៦% |
| -អាករពិសេសលើរបបនាំចូល | ៦៤% | +៣៧% | ✓កម្រៃគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ១៦% | –៥៥% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | ៥៨% | +១៤% | ✓នេសាទ | ២៥% | –១៥% |
| -អាករនាំចេញ | ១៣% | –៤២% | ✓ វុក្ខាប្រមាញ់ | ៣៤% | – |
| -អាករបន្ថែមលើផលិផលតេលសិលា | ៥២% | +១១% | ✓សម្បទានរ៉ែ | ១៨% | +២៣២,៧% |
| ✓ ចំណូលពន្ធដារ(**អ.នា ពន្ធដារ**) | ៦៨% | +១៨% | ✓អាកាសចរណ៍ស៊ីវិល | ៥៤% | +៣៦,៨% |
| -ពន្ធលើប្រាក់បៀវត្ស | ៥៧% | +២៣% | ✓ ផលទុនទេសចរណ៍ | ៤០% | +៣៣,៥% |
| - ពន្ធលើប្រាក់ចំណេញ | ៧៥% | +២៥% | ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១២% | +២៣,៨% |
| - ពន្ធលើឈ្នួលផ្ទះ–ដី | ៦៣% | +៣៦% | ✓អាករស្ថានទូត (លិខិតឆ្លងដែន និងទិដ្ឋាការ) | ៤៥% | +១៨% |
| - អាករលើផលរបរ | ២% | –៩៦% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ២៧% | +២៤៩% |
| - អាករលើតម្លៃបន្ថែម | ៥២% | +១៨% | ✓ ជួលសហគ្រាស សម្ភារៈ | ១០% | +២៤% |
| -អាករពិសេស | ៥៥% | +២០% | ✓លក់អចលនកម្ម (ទ្រព្យសម្បត្តិរដ្ឋ) | | –១០០% |
| -ចំណូលផ្សេងៗ | ៧២% | +១៤% | ✓ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | | +២៣% |
| -ថវិកាខេត្ត–រាជធានី | ៣២% | –១៦% | | | |
| | | | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០១៦ អនុវត្តបានចំនួន ៤៦២៤ប៊ីលានរៀល ស្មើនឹង ៣៤% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន ៣៩៣២ប៊ីលានរៀល ស្មើនឹង៣៥% នៃផែនការ និងចំណាយមូលធនមានចំនួន៦៩១,៩ប៊ីលានរៀល។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០១៥ ចំណាយថវិកាជាតិ កើនឡើង៣៨% ក្នុងនោះ ចំណាយចរន្ត កើនឡើង ៤២% និងចំណាយមូលធន ២០,១%។

➢ថវិកាជាតិនាឆមាសទី១ ឆ្នាំ២០១៦ មានអតិរេកចំនួន ២៧៤៥ ប៊ីលានរៀល ស្មើនឹង ៦៨៦,២៥ លានដុល្លារ ស.រ.អា។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៦មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ M2 មានចំនួន៥៤៧៣ប៊ីលានរៀល កើនឡើង ១៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៥។

➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ ៨% ប្រាក់បញ្ញើចរន្ត ១១%ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៥៦% និងប្រាក់បញ្ញើជារូបិយបណ្ណ ១៨%។

➢ចំនួនប្រាក់រៀលនៅក្នុងនិងក្រៅធនាគារសរុបមានចំនួន ១៦,៨% នៃរូបិយវត្ថុ M2 រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,២%។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុកម្ពុជានាចុងឆមាសទី១ ឆ្នាំ២០១៦



➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ៥៧៣០លានដុល្លារ កើនឡើង២៥% ធៀបនឹងឆមាសទី១ឆ្នាំ២០១៥ ។

➢**ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា** ជាទូទៅមានការកើនឡើង ដោយក្នុងឆមាសទី១ឆ្នាំ២០១៦ មានចំនួន ១៧២៩៩ ប៊ីលានរៀល កើនឡើង ២៧% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០១៥។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន ៥៤៣៥២ប៊ីលានរៀល កើនឡើង ២៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៥ ។

➢***អត្រាការប្រាក់ប្រចាំឆ្នាំ៖***

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៦ | ចុងឆមាសទី១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៧៩% | ៦,៧៦% | ០,៥% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៧,៣៤% | ១៦,១៩% | ៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៥២% | ៤,៣៧% | ៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៧៤% | ១១,៥៣% | ២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ២៨,៨% | ៣០,៦% | -៦% |
| អត្រាការប្រាក់កម្ចីជារៀលនៅបាក្លាកសិករ | ៣៨% | ៣១% | ២៣% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ២២,៨% | ២២,៨% | ០% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០១៦ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➡កសិកម្មៈ

➢តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១៤ ២០១៥ និង៦ខែដើមឆ្នាំ២០១៦។

| *ប្រភេទដំណាំ* | *ឆមាសទី១-២០១៦* | ឆ្នាំ២០១៥ | ឆ្នាំ២០១៤ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | | ២៥៦២ | ២៥៦៥ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | | ១១២,៦ | ១១៥,០ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | | | ៤៧០,៤ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | | ៥,៨ | ៤,០ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | | ៤៧,៤ | ៣០,៦ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | | ៥៧,២ | ៤០,៨ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | | ១៥,៥ | ១៥,១ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | | ៦៦,៨ | ៧២,៤ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា)<br>ក្នុងនោះ ផ្ទៃដីចៀរជ័រ | | ៣៨៩<br>១១១,២ | ៣៥៨,៩<br>៩០,៥ |

➢ ផលិតផលនេសាទមានចំនួន **២៨៧ពាន់តោន** ថយចុះ៧% បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ២០១៥។

➡ឧស្សាហកម្ម:

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៣៤៨ GWh កើនឡើង២១% ធៀបនឹងឆមាសទី១ឆ្នាំ២០១៥។ ក្នុងនោះ វារីអគ្គិសនីមានចំនួន ៤៩៥ GWh កើនឡើង ៣២% អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១៥៥៣,៨GWH កើនឡើង១៦% អគ្គិសនីផ្គត់ផ្គង់ដោយប្រេងខ្មៅ ៣៣៩,៨ GWh កើនឡើង ២២៨% និងអគ្គិសនីនាំចូលពីប្រទេសជិតខាងដោយ EDC ៩៣៩,៤ កើនឡើង២%។

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣២២១,២លានដុល្លារ កើនឡើង ៧% ធៀបនឹងឆមាសទី១ឆ្នាំ២០១៥។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០១៦ | ចំនួន:ឆមាសទី១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៧៧ | ៧៨ | -១% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥២០ | ១៣៧៤ | +១០% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៦៧ | ១៥៣ | +៩% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៦០ | ៨៣ | +៩៣% |

➡សំណង់:

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១០៥១២,៣ពាន់ម៉² កើនឡើង៣២៦%បើធៀបនឹងឆមាសទី១ ឆ្នាំ ២០១៥។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ៦៨៣៣,៤លានដុល្លារ កើនឡើង៧៤៥% បើធៀបនឹង៦ខែដើមឆ្នាំ ២០១៥។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន៖

| *ប្រភេទសំណង់* | ពាន់ម៉² :ឆមាសទី១ ឆ្នាំ២០១៦ | ពាន់ម៉² :ឆមាសទី១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៣៦៧៥ | ១២៧៨,០ | +១៨៨% |
| ឧស្សាហកម្ម | ១២៨០ | ៥៥៧,៩ | +១២៩% |
| ពាណិជ្ជកម្ម | ៥៣១៨,៣ | ៤៦១,២ | +១០៥៣% |
| ទេសចរណ៍ | ២០០,៤ | ៩៧,៦ | +១០៥% |
| ... | | | |
| អនុញ្ញាតសរុប | ១០៥១២,៣ | ២៤៦៨,៤ | +៣២៦% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ ឆ្នាំនេះ សំណង់ដែលពេញនិយមគឺពាណិជ្ជកម្ម (៥០,៦% នៃផ្ទៃក្រឡាសរុប) និងលំនៅដ្ឋាន (៣៥% នៃផ្ទៃក្រឡាសរុប)។

➡ការងារ:

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៦ (នាក់) | ឆមាសទី១ ឆ្នាំ ២០១៥ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារមុខរបរ និងការងារ) | ៥៥៧៩ | ៥២៨៣ | +៦% |
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ៦១៧០២ | ៣៦៦៩៧ | +៦៨% |
| អ្នកទទួលបានការធ្វើក្នុងប្រទេស | ៤៦២៨៦ | ២៣០៥៧ | +១០១% |
| អ្នកទទួលបានការធ្វើក្រៅប្រទេស | ១៥៤១៦ | ១៣៦៤០ | +១៣% |

➡វិនិយោគ:

➢គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក) (មិនទាន់មានតួលេខ)

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៦ | ឆមាសទី១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ១៨៧៩,៨ | ៣៣១៥,៨ | -៤៣% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៧៤,៦ | ៣៥២,៦ | -៧៩% |
| វិស័យឧស្សាហកម្ម | ៧៧០,៥ | ៣៥៩,៩ | +១១៤% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ៥៨,៤ | ៧២,៣ | -១៩% |
| វិស័យទេសចរណ៍ | ៦៦៤,៧ | ៧៣,៩ | +៨០០% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៣៧០,០ | ២៥២៩,៤ | -៨៥% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ៧៩,០ | ៩៤ | -១៦% |
| **បង្កើតការងារ (ពាន់នាក់)** | ៧៦,៤ | ១០៦,២ | -២៨% |

➡សេវាកម្ម និងទេសចរណ៍:

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី៖

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ២០១៦ | *ចំនួន* :ឆមាស១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | ២២០៦ | |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | ១៨ | |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ៧៨៩ | |

➢**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប៥កំពង់ផែ)មានចំនួន៤៦៣៧,០ពាន់តោន ថយចុះ0% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៥។ ក្នុងនោះ៖

| *ប្រភេទ* | ឆមាសទី១ ឆ្នាំ២០១៦ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៥(ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១២០៩ | ១០៨៩,២ | +១១% |
| កំពង់ផែកំពង់សោម | ២៩០៨,៧ | ២៧១៣,៧ | +៧% |
| កំពង់ផែស្រែអំបិល និងកោះកុង | ២២៧,៩ | ៣៣៩,៨ | –៣៣% |
| កំពង់ផែឧកញ៉ាម៉ុង | ២៩១,៥ | ៤៩៥,២ | –៤១% |

➢អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៦(ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៥(ពាន់នាក់) | បម្រែបម្រួល |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១២៤,១ | ៨៩,៣ | +៣៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | | ២២២,១ | |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | | ២៨០១,៦ | |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | | ៥៥៣,០ | |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | | ២៣០២,០ | |
| ✓តាមផ្លូវអាកាស | | ១២៣០,៩ | |
| ✓ តាមផ្លូវគោក និងទឹក | | ១០៧១,១ | |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៦ | ឆមាសទី១ ឆ្នាំ២០១៥ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៨៦,០ | ៧០,៣ | ២២% |
| ក្នុងនោះទទួល | ១២,៨ | ១១,០ | ១៧% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៦២៨,៨ | ៦៣៣,០ | -១% |
| ក្នុងនោះទទួល | ២៩០,៥ | ២៦០,៣ | ១២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៦ ៩៨៧,៣ | ២១ ២៥១,០ | -២០% |
| ក្នុងនោះហៅចូល | ៤ ៩៣០,៤ | ៥ ៩០៨,៣ | -១៧% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៦៦ ៣៥០,៨ | ៦៨ ០០៥,៦ | -២% |
| ក្នុងនោះហៅចូល | ៦៦ ០៣១,០ | ៦៧ ៥១៥,២ | -២% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ៖

➡**ការនាំចូល**ក្នុងឆមាសទី១ ឆ្នាំ២០១៦ មានចំនួន ២៥៨០០ពាន់លានរៀល កើនឡើង ៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៥។ ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន៖

| បរិយាយ | %Δធៀបនឹងឆ.ទី១ ឆ្នាំ២០១៥ | បរិយាយ | %Δធៀបនឹងឆ.ទី១ ឆ្នាំ២០១៥ |
|---|---|---|---|
| ប្រេងសាំង | +៨% | ត្រាក់ទ័រនិងគោយន្ត(ជាគ្រឿង) | -២៦% |
| ប្រេងម៉ាស៊ូត | +១៥% | ម៉ូតូ(ជាគ្រឿង) | +១៨% |
| ឧស្ម័ន | +២៦% | អង្ករ | -៤៤% |
| ប្រេងខ្មៅ | +៣០៦% | ផ្លែឈើនិងបន្លែ | -១២% |
| អគ្គិសនីនាំចូល | +២% | ជីនិងថ្នាំកសិកម្ម | +៩% |
| ដែកសំណង់ | +៤៨% | បារី | +១៦% |
| ស៊ីម៉ង់ត៍ | -២៧% | ភេសជ្ជៈ | +១៨% |
| គ្រឿងអេឡិចត្រូនិក | +១៤៨% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៩% |
| រថយន្តសរុប (ជា ព.ល.រ) | +២០% | | |
| រថយន្តសរុប (ជាគ្រឿង) | +៣៧% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០១៦ មានចំនួន ១៩១៦៩ប៊ីលានរៀលកើនឡើង ១៤% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៥។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៥ | ទំនិញ | %∆ធៀបនឹងឆ.ទី១ ឆ្នាំ២០១៥ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៦៣% | ផលិតផលនេសាទ | -៤៤% |
| វាយនភណ្ឌនិងស្បែកជើង | +៩% | កៅស៊ូ | -២០% |
| អង្ករ | -៧% | | |

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆមាសទី១ ឆ្នាំ២០១៦សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | % ∆ ធៀបនឹងឆមាស១ ឆ្នាំ២០១៤ | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ថ្លៃសាច់គោ | +១០,៥% | — |
| ២ | ថ្លៃត្រីស្រស់ | +១០,៣% | — |
| ៣ | ថ្លៃបន្លែ | +៥,៩% | — |
| ៤ | អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | +៧% | |
| ៥ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក | -៤៣% | — |

## ៧) សេចក្តីសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ៗ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) ក្នុងឆមាសទី១ ឆ្នាំ២០១៦ សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាសម្រេចបានសមិទ្ធិផលវិជ្ជមានគួរឲ្យកត់សម្គាល់មួយចំនួន ដូចជា ចំណូលថវិកាជាតិ ឥណទាន សំណង់ និងការនាំចេញមានការកើនឡើងធៀបនឹងឆមាសទី១ឆ្នាំ២០១៥។ ប៉ុន្តែទន្ទឹមនឹងនោះក៏មានបញ្ហាប្រឈមគួរចាប់អារម្មណ៍ ដូចជា ការកើនថ្លៃទំនិញ ជាពិសេស សាច់គោ និងត្រី កំណើនអត្រាការប្រាក់កម្ចី និងការវិនិយោគបរទេសមានការថយចុះ។

២) វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រឈមនឹងបញ្ហាការវិនិយោគទាប និងមានកំណើនទាប ទាំងក្នុងវិស័យដាំដុះ ទាំងវិស័យចិញ្ចឹមសត្វ។

៣) វិស័យគន្លឹះដែលជាចលករនៃសេដ្ឋកិច្ចជាតិបច្ចុប្បន្នគឺ សំណង់អចលនទ្រព្យ និងវិនិយោគផ្ទាល់ពីបរទេស។ គួរកត់សម្គាល់ថា សំណង់មានកំណើនខ្ពស់ រីឯការវិនិយោគបង្ហាញការថយចុះធៀបនឹងឆមាសទី១ ឆ្នាំ២០១៥ ។

៤) ដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ ទាមទារការទាក់ទាញវិនិយោគបរទេស ជាពិសេសក្នុងវិស័យឧស្សាហកម្ម និងកសិកម្ម ជំរុញការវិនិយោគក្នុងស្រុក និងការគ្រប់គ្រងអត្រាការប្រាក់ជាវិធានការចម្បង។

៥) សុវត្ថិភាព និងគុណភាពចំណីអាហារដែលអង្គប្រជុំបានពិភាក្សាជាច្រើនសារហើយនោះ ត្រូវបានអង្គប្រជុំលើកយកមកពិភាក្សាទៀតយ៉ាងផុសផុល ដោយសារបញ្ហានេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងអាយុជីវិតរបស់អ្នកបរិភោគទូទាំងប្រទេសដែលតម្រូវឲ្យមានវិធានការចាំបាច់ក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់។ **ជាដំណោះស្រាយ** អង្គប្រជុំបានលើកឡើងម្តងទៀត**អំពីសារៈសំខាន់នៃការបង្កើតស្ថាប័នឯករាជ**និងមានទំនុកចិត្តដើម្បីទទួលបន្ទុកគ្រប់គ្រងសុវត្ថិភាពនិងគុណភាពចំណីអាហារ ទាំងផលិតក្នុងស្រុក នាំចូល ទាំងការរក្សាទុកនិងអនាម័យ។

ស្ថាប័នគ្រប់គ្រងសុវត្ថិភាព និងគុណភាពចំណីអាហារត្រូវមានសមត្ថភាព និងលទ្ធភាពពេញលេញក្នុងការបំពេញភារៈកិច្ចរបស់ខ្លួនដើម្បីឲ្យមានប្រសិទ្ធភាពខ្ពស់។ ដូច្នេះត្រូវមានថវិកា មន្ទីរពិសោធន៍បំពាក់ដោយឧបករណ៍គ្រប់គ្រាន់សម្រាប់ពិនិត្យ និងវិភាគទៅតាមស្តង់ដារអន្តរជាតិ វាយតម្លៃសុវត្ថិភាពនិងគុណភាពចំណីអាហារដែលចែកចាយទូទាំងប្រទេស និងផ្តល់ព័ត៌មានជូនរាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់ឲ្យបានទាន់ពេលវេលា។ ស្ថាប័ននេះត្រូវសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរក្សាសុវត្ថិភាព និងគុណភាពចំណីអាហារ ហើយត្រូវសហការជាមួយអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងៗទៀត ក្នុងការពង្រឹងសមត្ថភាព និងគាំទ្របច្ចេកទេសអំពីសុវត្ថិភាព និងគុណភាពចំណីអាហារ។l

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៧/១៦<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៥/០៧/១៦<br>ម៉ោង១៨:០០នាទី | ចូលរួមជាអធិបតី ក្នុងកម្មពិធីបើកសម្ពោធ Artisans Angkor Concept Store នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ៣ | ០៦/០៧/១៦<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៧-២០១៩។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៨/០៧/១៦<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។<br>២-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៧-២០១៩។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១-កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣។<br>៣.២-ពិធីសារដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា។<br>៣.៣-កិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន។<br>៣.៤-ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន។<br>៣.៥-ពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន។<br>៣.៦-ពិធីសារទី៧ ស្តីពីប្រព័ន្ធឆ្លងកាត់គយ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៥ | ០៨/០៧/១៦<br>ម៉ោង១៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពិសារអាហារពេលល្ងាចជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង និងឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ក្នុងឱកាសជូនដំណើរឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ជម្រាបលា នៅស្ថានទូតបារាំង។ |
| ៦ | ១៤/០៧/១៦<br>ម៉ោង១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងកម្មវិធីបុណ្យជាតិ នៃសាធារណរដ្ឋបារាំង នៅស្ថានទូត។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១៨/០៧/១៦ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារអំពីការសាងសង់ក្លោងទ្វារ "A" នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាមួយលោក **លី រស្មី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៩/០៧/១៦ ម៉ោង០៨:០០នាទី | ចូលរួមប្រជុំស្តាប់ការផ្សព្វផ្សាយ "របាយការណ៍ស្តីពីសភាពការណ៍ទូទៅឆមាសទី១ និងទិសដៅភារកិច្ចរបស់គណបក្សឆមាសទី២ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នៅទីស្នាក់ការកណ្តាលគណបក្ស។ |
| ៩ | ២០/០៧/១៦ ម៉ោង០៩:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីបញ្ចុះបឋមសិលាដំណាក់កាលទី២ នៃការពង្រីកស្ថានីយអ្នកដំណើរនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ១០ | ២១/០៧/១៦ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសម្របសម្រួល និងសហការជាមួយភាគីចិន ដើម្បីពិភាក្សា និងពិនិត្យលើគួប្លង់ដំបូងនៃគម្រោងសាងសង់អគារអង្គរក្សនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ២២/០៧/១៦ ម៉ោង១០:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ប្រាក់ មិន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២២/០៧/១៦ ម៉ោង១៦:០០នាទី | ចូលរួមកិច្ចប្រជុំការងារចាំបាច់របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូល ដ្ឋានខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ២៦/០៧/១៦ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំ និងពិភាក្សាលើស្ថានភាពអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម **ឌិន ទីរៈ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ២៨/០៧/១៦ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆមាសទី១ ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៨/០៧/១៦ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមិថុនា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៩/០៧/១៦ ម៉ោង០៨:៣០នាទី | ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីការរៀបចំបង្កើតសមាគមមូលនិធិគ្រូបង្រៀន បណ្ឌិតសភាចារ្យ **សុខ អាន** ស្រុកកោះអណ្តែត ទ្រាំង សំរោង អង្គរបូរី និងបូរីជលសារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងជាប្រធានសមាគមមូលនិធិគ្រូបង្រៀន បណ្ឌិតសភាចារ្យ **សុខ អាន** តាកែវ នៅមន្ទីរ ៧មករា ខេត្តតាកែវ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in